# គោលនយោបាយ

# រដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

"កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្ត ប្រជាពលរដ្ឋ
តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ"



# សេចក្ដីផ្ដើម

# ភាពចាំបាច់នៃគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២ - ២០៣៥



# កម្រិតរដ្ឋាភិបាលឌីជីថល - និយមន័យ

### រដ្ឋាភិបាលអេឡិចត្រូនិក

- ហេដ្ឋារចនាសម្ព័ន្ធមិនទាន់តភ្ជាប់គ្នា
- ប្រព័ន្ធព័ត៌មានឌីជីថលដាច់ដោយឡែក
- មិនទាន់ធ្វើសមាហរណកម្ម

### រដ្ឋាភិបាលបើកចំហ

- មតិយោបល់ពីប្រជាពលរដ្ឋ
- អន្តរសកម្មរវាងអ្នកផ្តល់និងអ្នកទទួលសេវា
- ព័ត៌មានត្រូវបានបើកចំហ

### រដ្ឋាភិបាលផ្តោតលើទិន្នន័យ

- ទិន្នន័យជាទ្រព្យសំខាន់
- ការប្រមូល ការប្រើប្រាស់ និងការវិភាគទិន្នន័យ
- ធ្វើសមាហរណកម្មជាបណ្តើរៗ

**២០២២-២០២៥**

### រដ្ឋាភិបាលបរិវត្តកម្មពេញលេញ

- ធ្វើសមាហរណកម្មចូលគ្នាពេញលេញ
- ការប្រើប្រាស់ ការគ្រប់គ្រង និងការការពារទិន្នន័យមានលក្ខណៈល្អប្រសើរ

**២០២៦-២០៣០**

### រដ្ឋាភិបាលឆ្លាត

- ការប្រមូលនិងការវិភាគទិន្នន័យដោយស្វ័យប្រវត្តិ
- ការសម្រេចចិត្តផ្អែកលើទិន្នន័យ
- នវានុវត្តន៍នៃសេវាសាធារណៈ ដោយប្រើប្រាស់បច្ចេកវិទ្យាឈានមុខ

**២០៣១-២០៣៥**

# អត្ថប្រយោជន៍នៃរដ្ឋាភិបាលឌីជីថល

ភាពរឹងមាំនៃក្រសួងស្ថាប័នរដ្ឋ

សេវាសាធារណៈឆាប់រហ័ស និងមានតម្លាភាព
ឆ្លើយតបតាមតម្រូវការប្រជាពលរដ្ឋ




កំណើនអ៊ីនធឺណិតល្បឿនលឿនជំរុញ
កំណើនផលិតផលក្នុងស្រុកសរុប

ភាពប្រសើរឡើងនៃប្រព័ន្ធអេកូឡូស៊ីឌីជីថល
ដែលផ្តល់មូលដ្ឋានគ្រឹះ
និងបរិយាកាសអំណោយផលសម្រាប់
ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល

# ស្ថានភាពបច្ចុប្បន្ននៃវិស័យទូរគមនាគមន៍

ចំនួនការជាវសេវាទូរសព្ទចល័តសរុប 20,535,928 ( មិថុនា 2021 )




ចំនួនការជាវសេវាអ៊ីនធឺណេតអចល័តសរុប 304,071( មិថុនា 2021 )



# ស្ថានភាពបច្ចុប្បន្ននៃវិស័យទូរគមនាគមន៍ (ត)




**បណ្តាញខ្សែកាប្លិ៍អុបទិកឆ្អឹងខ្នងសរុប 45,933 គ.ម[1]**

ដែលមានសមត្ថភាពបញ្ជូនទិន្នន័យ STM-1 (155Mbps), STM-64 (9953Mbps) និង បច្ចេកវិទ្យា (Dense Wavelength Division Multiplexing – DWDM) (32Tbps, 64Tbps)

- CFOCN = 17,099 គ.ម
- TC = 2,180 គ.ម
- Viettel (Cambodia) = 26,654 គ.ម

**បំពង់ផ្លូវកាប្លិ៍ក្រោមដីសរុប 2,424 គ.ម[1]**

- CFOCN = 2,313 គ.ម
- TC = 111 គ.ម

(1) គិតត្រឹមខែមីនា ២០២១

# ស្ថានភាពបច្ចុប្បន្ននៃរដ្ឋាភិបាលឌីជីថលកម្ពុជា




● រាល់ឯកសារដែលចូលការិយាល័យច្រកចេញចូលតែមួយ ត្រូវប្រគល់បន្តអោយក្រសួងស្ថាប័នសាមី ● ហាដវែរ និងបណ្តាញរបស់ក្រសួងស្ថាប័នមានលក្ខណៈដាច់ដោយឡែកពីគ្នា ● ក្របខណ្ឌដំណើរការ និងទម្រង់ពុំទាន់មានស្តង់ដាររួម ● កង្វះការចែករំលែកព័ត៌មានពីស្ថាប័នមួយទៅស្ថាប័នមួយ

# គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា
# ២០២២ - ២០៣៥




# ចក្ខុវិស័យ

“ កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ ”

## គោលដៅជាយុទ្ធសាស្ត្រ

១
ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល

២
ការកសាងអភិបាលកិច្ចនិងសេវាសាធារណៈឌីជីថល

៣
ការកសាងសមត្ថភាពនិងនវានុវត្តន៍ឌីជីថល

៤
ការលើកកម្ពស់កិច្ចសហការនិងភាពជាដៃគូរវាងរដ្ឋនិងឯកជន

# គោលដៅយុទ្ធសាស្ត្រទី១

## ការអភិវឌ្ឍ
## ហេដ្ឋារចនាសម្ព័ន្ធ
## រដ្ឋាភិបាលឌីជីថល



**គោលដៅ**
**ជាយុទ្ធសាស្ត្រទី១**

**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល**

**យុទ្ធសាស្ត្រទី១**
ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល

1- ជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល
2- បង្កើតមជ្ឈមណ្ឌលទិន្នន័យជាតិ
3- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបណ្តាញរដ្ឋាភិបាលឌីជីថល
4- ជំរុញការអភិវឌ្ឍអេកូស៊ីស្តែមនៃប្រព័ន្ធផ្គាយរណប
5- ពង្រឹងនិងពង្រីកថ្នាលផ្លាស់ប្តូរទិន្នន័យ
6- ជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ

**យុទ្ធសាស្ត្រទី២**
ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ

7- រៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារទូទាត់សងប្រាក់ថ្នាក់ជាតិសម្រាប់សេវាសាធារណៈ

**យុទ្ធសាស្ត្រទី៣**
ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល

8- ពង្រឹងប្រព័ន្ធគ្រប់គ្រង និងការពារសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
9- រៀបចំនិងពង្រឹងសន្តិសុខច្រកទ្វារអ៊ីនធឺណិតជាតិ
10- រៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល

**យុទ្ធសាស្ត្រទី៤**
ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍

11- រៀបចំនិងកែលម្អប្រព័ន្ធបណ្តាញប្រៃសណីយ៍ជាតិ

# គោលដៅយុទ្ធសាស្ត្រទី២

## ការកសាង
## អភិបាលកិច្ចនិង
## សេវាសាធារណៈឌីជីថល



## គោលដៅ ជាយុទ្ធសាស្ត្រទី២

## ការកសាងអភិបាលកិច្ច និងសេវាសាធារណៈឌីជីថល

**យុទ្ធសាស្ត្រទី៥**
ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល

**យុទ្ធសាស្ត្រទី៦**
ការធ្វើបរិវត្តកម្មឌីជីថលនៃរដ្ឋាភិបាល និងសេវាសាធារណៈ

. . .

12- រៀបចំគោលនយោបាយអភិបាលកិច្ចទិន្នន័យ
13- រៀបចំគោលនយោបាយទិន្នន័យបើកចំហ
14- រៀបចំគោលនយោបាយជំរុញអភិវឌ្ឍនិងការប្រើប្រាស់សុសវែរ
15- រៀបចំគោលនយោបាយឌីជីថលសម្រាប់ទីក្រុងឆ្លាត
16- រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍវិស័យប្រៃសណីយ៍
17- រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល
18- រៀបចំច្បាប់ស្ដីពីរដ្ឋាភិបាលឌីជីថល
19- រៀបចំច្បាប់ស្ដីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
20- រៀបចំច្បាប់ស្ដីពីការការពារទិន្នន័យឯកជនរបស់បុគ្គល
21- រៀបចំនិងវិសោធនកម្មច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងច្បាប់ស្ដីពីទូរគមនាគមន៍
22- រៀបចំបទដ្ឋាននិងសេចក្ដីណែនាំស្ដីពីហត្ថលេខាឌីជីថល
23- រៀបចំច្បាប់ស្ដីពីសេវាប្រៃសណីយ៍
24- រៀបចំច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន
25- រៀបចំនិងវិសោធនកម្មច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និងការត្រួតពិនិត្យលើការបង្ហោះ និងបង្កើតនូវខ្លឹមសារ
26- រៀបចំស្ដង់ដាការងាររដ្ឋបាល
27- រៀបចំស្ដង់ដាបច្ចេកសព្ទឌីជីថលរដ្ឋបាល
28- រៀបចំស្ដង់ដាសេវារដ្ឋាភិបាលឌីជីថល
29- រៀបចំស្ដង់ដាស្ដីពីការគ្រប់គ្រងសេវាឌីជីថល
30- រៀបចំស្ដង់ដាវិស្វកម្មសុសវែរនិងប្រព័ន្ធព័ត៌មាន
31- រៀបចំស្ដង់ដាសន្តិសុខព័ត៌មាន
32- រៀបចំស្ដង់ដាសម្រាប់ទីក្រុងឆ្លាត
33- រៀបចំស្ដង់ដាមជ្ឈមណ្ឌលទិន្នន័យ
34- រៀបចំស្ដង់ដាបច្ចេកវិទ្យាឌីជីថលចុងក្រោយ
35- រៀបចំនិម្មាបនកម្មរដ្ឋាភិបាលឌីជីថល

យុទ្ធសាស្ត្រទី៥
ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល

. . .

## គោលដៅ
## ជាយុទ្ធសាស្ត្រទី២

## ការកសាងអភិបាលកិច្ច និងសេវាសាធារណៈឌីជីថល

យុទ្ធសាស្ត្រទី៦
ការធ្វើបរិវត្តកម្មឌីជីថលនៃរដ្ឋាភិបាលនិងសេវាសាធារណៈ

36- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវថ្នាលសហការកិច្ចការរដ្ឋបាល (Collaboration Platform)

37- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការរួម

38- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុរួម

39- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងឯកសារអេឡិចត្រូនិករួមនិងប្រព័ន្ធផ្តល់សច្ចានុម័តអេឡិចត្រូនិករួម

40- រៀបចំនិងបំពាក់ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ឌីជីថល សុសវែរ និងប្រព័ន្ធព័ត៌មានចាំបាច់នានា

41- រៀបចំនិងធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងព័ត៌មានភូមិសាស្ត្រ

42- រៀបចំមូលដ្ឋានទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ (National Infrastructure Management Information System)

43- រៀបចំប្រព័ន្ធគ្រប់គ្រងចំណេះដឹង (Knowledge Management System)

44- រៀបចំថ្នាលសេវាច្រកចេញចូលតែមួយ

45- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្រានុកូលដ្ឋាន

46- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្តសញ្ញាណកម្ម

47- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានជនអន្តោប្រវេសន៍ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានទិដ្ឋាការ

48- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានស្នាក់នៅ និងគ្រួសារ

49- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអចលនវត្ថុ

50- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានយានយន្តនិងប័ណ្ណបើកបរយានយន្ត

51- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរសព្ទសេវាបន្ទាន់ជូនប្រជាពលរដ្ឋ

52- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

53- រៀបចំ និងកែលម្អឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានទីផ្សារការងារនិងសេវាជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋ

54- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរួមនិងគ្រប់គ្រងសេវា

55- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានទេសចរណ៍រួម

56- រៀបចំនិងកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានកសិកម្ម

57- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រង ព័ត៌មានគ្រោះមហន្តរាយនិងប្រព័ន្ធផ្តល់ដំណឹងជាមុនជូនប្រជាពលរដ្ឋពាក់ព័ន្ធនឹងគ្រោះមហន្តរាយ គ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ

58- ជំរុញនិងរៀបចំប្រព័ន្ធអេកូឡូស៊ីប្រៃសណីយ៍ឌីជីថល

59- ធ្វើទំនើបកម្មការគ្រប់គ្រងនិងសេវាប្រៃសណីយ៍

60- រៀបចំនិងកែលម្អថ្នាលចុះបញ្ជីអាជីវកម្មរួម

61- រៀបចំប្រព័ន្ធគ្រប់គ្រងលទ្ធកម្មអេឡិចត្រូនិក (e-Procurement)

62- រៀបចំនិងកែលម្អប្រព័ន្ធសេវាពន្ធដារឌីជីថល

63- រៀបចំនិងកែលម្អប្រព័ន្ធបញ្ជរតែមួយជាតិ

# គោលដៅយុទ្ធសាស្ត្រទី៣

## ការកសាងសមត្ថភាពនិង ឆទានុវត្តន៍ជីវីផល



## គោលដៅជាយុទ្ធសាស្ត្រទី៣
## ការកសាងសមត្ថភាព និងនវានុវត្តន៍ឌីជីថល

### យុទ្ធសាស្ត្រទី៧ ការកសាងមូលធនមនុស្សឌីជីថល

64- រៀបចំយន្តការនៃការវាស់វែងកម្រិតសមត្ថភាព និងយន្តការនៃការគ្រប់គ្រងនិងរក្សាទុកមូលធនមនុស្សជំនាញឌីជីថលក្នុងវិស័យសាធារណៈ

65- ជំរុញការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ឌីជីថល

66- ជំរុញការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល និងជំនាញឌីជីថលចាំបាច់នានាដល់ថ្នាក់ដឹកនាំមន្ត្រីរាជការនិងបុគ្គលិកក្រសួងស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងក្រោមជាតិ ជាពិសេសមន្ត្រីបង្គោលបច្ចេកវិទ្យា

67- ជំរុញការរៀបចំនិងកែលម្អកម្មវិធីសិក្សាដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់សិស្សនិស្សិត គ្រប់កម្រិតសិក្សានិងបណ្តុះបណ្តាល

68- លើកកម្ពស់អក្ខរកម្ម និងវិធីសាស្ត្របង្រៀនឌីជីថល សម្រាប់គ្រូបង្រៀនគ្រប់កម្រិតសិក្សានិងបណ្តុះបណ្តាល

69- ជំរុញការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអប់រំចាំបាច់ ដើម្បីគាំទ្រដល់ការអប់រំ និងការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល ដល់ស្ថាប័នអប់រំគ្រប់កម្រិតនិងបណ្តុះបណ្តាល

70- រៀបចំនូវកម្មវិធីបណ្តុះបណ្តាល កម្មវិធីបញ្ជ្រាបការយល់ដឹង និងការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធផ្សព្វផ្សាយនានា

71- ជំរុញការរៀបចំថ្នាលអប់រំនិងបណ្តុះបណ្តាលជាតិរួម

72- រៀបចំក្របខណ្ឌជាតិសមត្ថភាពឌីជីថល

73- ពង្រឹងនិងពង្រីកស្ថាប័នបណ្តុះបណ្តាលជំនាញឌីជីថល

74- រៀបចំកម្មវិធីតម្រង់ទិស ផ្សព្វផ្សាយ និងលើកទឹកចិត្ត ដើម្បីជំរុញឱ្យយុវជន យុវនារី និងស្ត្រីជ្រើសរើសជំនាញបច្ចេកវិទ្យាឌីជីថល

75- ជំរុញការបណ្តុះបណ្តាលអ្នកជំនាញឌីជីថល

### យុទ្ធសាស្ត្រទី៨ ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល

76- ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល

77- ជំរុញការផ្ទេរបច្ចេកវិទ្យាឌីជីថល ដែលបានពីការស្រាវជ្រាវដល់វិស័យសាធារណៈ និង ឯកជន

78- ជំរុញសហគ្រិន និងនវានុវត្តន៍ឌីជីថល និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន

# គោលដៅយុទ្ធសាស្ត្រទី៤

## ការលើកកម្ពស់កិច្ចសហការ
## និងភាពជាដៃគូ
## រវាងរដ្ឋនិងឯកជន



យុទ្ធសាស្រ្តទី៩
ការរៀបចំសហការ
ជាមួយក្រុមហ៊ុន
បច្ចេកវិទ្យា ឌីជីថល

គោលដៅ
ជាយុទ្ធសាស្រ្តទី៤

ការលើកកម្ពស់កិច្ច
សហការនិងភាពជា
ដៃគូរវាងរដ្ឋនិង
ឯកជន

យុទ្ធសាស្រ្តទី១០
ការលើកកម្ពស់ធុរកិច្ច
ថ្មីឌីជីថល

79- រៀបចំវេទិការវាងគណៈកម្មការរដ្ឋាភិបាលឌីជីថល និងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល

80- ជំរុញការផ្សព្វផ្សាយនិងសម្របសម្រួល និងលើកទឹកចិត្តក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ក្នុងការចូលរួមអភិវឌ្ឍ និងផ្គត់ផ្គង់ការរៀបចំប្រព័ន្ធ និងសេវាបច្ចេកវិទ្យាឌីជីថល

81- ជំរុញកិច្ចសហការជាមួយប្រតិបត្តិករវិស័យប្រៃសណីយ៍ និងវិស័យផ្សេងទៀតក្នុងការចូលរួមផ្តល់សេវារដ្ឋាភិបាលឌីជីថល

82- បង្កើតនិងពង្រឹងសេវាគាំទ្រនិងលើកទឹកចិត្តការបង្កើតធុរកិច្ចថ្មីឌីជីថល

83- ពង្រឹងឱកាសទីផ្សារសម្រាប់ធុរកិច្ចថ្មីឌីជីថល

# យន្តការដឹកនាំ សម្របសម្រួល និង អនុវត្ត

# រចនាសម្ព័ន្ធ

- ក្រុមប្រឹក្សាជាតិ សេដ្ឋកិច្ចនិងសង្គមឌីជីថល
  - គណៈកម្មាធិការ រដ្ឋាភិបាលឌីជីថល
  - គណៈកម្មាធិការ សេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
  - គណៈកម្មាធិការ សន្តិសុខឌីជីថល

# រចនាសម្ព័ន្ធ (ត)


គណៈកម្មាធិការ
រដ្ឋាភិបាលឌីជីថល
ទីប្រឹក្សា
អគ្គលេខាធិការដ្ឋាន
ក្រុមការងារ
បច្ចេកទេសអន្តរក្រសួង

# អភិក្រមនៃការអនុវត្តន៍គម្រោង

## កសាងដំណាលគ្នា និងដាច់ដោយឡែកពីគ្នា



## កសាងមជ្ឈមណ្ឌលទិន្នន័យ ពាក់កណ្ដាលវិមជ្ឈការ



# ការគ្រប់គ្រងផលប៉ះពាល់ និងហានិភ័យ

## គ្រប់គ្រង ផលប៉ះពាល់

គ្រប់គ្រងនិងត្រួតពិនិត្យលើការបង្ហោះ
និងការបង្កើតមាតិកាផ្សេងៗ

អនុវត្តគម្រោងនិង/ឬកម្មវិធីជំរុញការ
យល់ដឹងអំពីវប្បធម៌ សិល្បៈ និងអរិយធម៌
តាមប្រព័ន្ធអេឡិចត្រូនិក

រៀបចំនិងអនុវត្តក្របខណ្ឌកម្មវិធីផ្សព្វផ្សាយ
ថ្នាក់ជាតិនិងជំរុញការអភិវឌ្ឍចំណេះដឹងនិងជំនាញ
ឌីជីថល និងការផ្តល់ប្រឹក្សាស្តីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

# គ្រប់គ្រងហានិភ័យទាំង ៥

## ការសម្របសម្រួលស្ថាប័ន

ប្រគល់សិទ្ធិអំណាចគ្រប់គ្រាន់ជូនអង្គភាពបរិវត្តកម្មឌីជីថល

## ការផ្លាស់ប្តូររបៀបការងារ

ពង្រឹងការយល់ដឹងពីផលប្រយោជន៍និងសារៈសំខាន់នៃរដ្ឋាភិបាលឌីជីថល

## ធនធានមនុស្សនិងហិរញ្ញវត្ថុ

លើកកម្ពស់អភិបាលកិច្ចល្អ និងលើកទឹកចិត្តប្រកបដោយសមធម៌

## សន្តិសុខឌីជីថល

រៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យមានសុវត្ថិភាពនិងភាពធន់ បំពេញឱ្យគ្នា និងចម្លងទិន្នន័យបម្រុងទុក

## ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា

រៀបចំផែនការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលច្បាស់លាស់

# លទ្ធផលសម្រេចនៃការ
# អនុវត្តគោលនយោបាយ
# ២០២២ - ២០៣៥


ប្រជាពលរដ្ឋ
-គ្រប់វ័យ និងយេនឌ័រ
-គ្រប់ទីកន្លែង
-គ្រប់ពេលវេលា
វិបផតថល G4C
សេវាពីរដ្ឋាភិបាល ដើម្បីប្រជាពលរដ្ឋ
សេវាកម្មល្អប្រសើរតាមដំណាក់កាលវដ្តជីវិត
N-ID
សមាហរណកម្មការគ្រប់គ្រងការអប់រំ
សេវាពីរដ្ឋាភិបាល ទៅធុរកិច្ច
ការបង់ពន្ធ
លទ្ធកម្មសាធារណៈ
ការចុះបញ្ជីពាណិជ្ជកម្ម
...
វិបផតថល G2B
ធុរកិច្ច
-ក្រុមហ៊ុនផលិត
-ក្រុមហ៊ុនពាណិជ្ជកម្ម
-ធនាគារ។ល។
សេវា ២៤ម៉ោង/១ថ្ងៃ ៣៦៥ថ្ងៃ
G2G
សេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល
ការគ្រប់គ្រងហិរញ្ញវត្ថុ
ការគ្រប់គ្រងរដ្ឋបាល
លំហូរការងារផ្ទៃក្នុង
រដ្ឋាភិបាល
ក្រសួងស្ថាប័ន
លំហូរការងារផ្ទៃក្នុង
ការគ្រប់គ្រងមន្ត្រីរាជការ
ការគ្រប់គ្រងឯកសារអេឡិចត្រូនិក
បណ្ដាញអ៊ីនធឺណិត
បណ្ដាញរដ្ឋាភិបាល
ហេដ្ឋារចនាសម្ព័ន្ធ
ទិន្នន័យជាតិ
បណ្ដាញរដ្ឋាភិបាល
ប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន
បច្ចេកវិទ្យាក្លោដ
មជ្ឈមណ្ឌលទិន្នន័យជាតិ
មជ្ឈមណ្ឌលស្ដារឡើងវិញ
ក្រសួងស្ថាប័នសាធារណៈ
ក្រសួង
ក្រសួង
ក្រសួង
មជ្ឈមណ្ឌលទិន្នន័យជាតិ

# សូមអរគុណ!



